ក្រសួងកិច្ចការនារី

# ព្រឹត្តិបត្រ នារីរតនៈ

## Neary Rattanak Newsletter

២០១៤. លេខ៤៩ ឆ្នាំទី៨



**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បំពាក់គ្រឿងឥស្សរិយយសថ្នាក់ជាតិ មហាសិរីវឌ្ឍន៍ ជូនកញ្ញា ស៊ន សៀវម៉ី**

ចេញផ្សាយពីនាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី
Organized by Information Department of Ministry of Women's Affairs
គេហទំព័រ: www.mowa.gov.kh

## គណៈកម្មការត្រួតពិនិត្យ

-លោកជំទាវ **ខេង សំវាដា** រដ្ឋលេខាធិការ

-លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិកា

-លោកស្រី **ឌី វ៉ានី** ប្រធាននាយកដ្ឋាន

-លោកស្រី **ឃិន សារ៉ាត់** អនុប្រធាននាយកដ្ឋាន

## គណៈកម្មការនិពន្ធ

-លោក **ប៉ែន ជា**

-លោកស្រី **កែវ វឌ្ឍនា**

-លោកស្រី **កែវ វណ្ណនី**

-លោកស្រី **តែ សុខខេង**

## ការីកុំព្យូទ័រ

-លោកស្រី **ប្រាក់ សោភា**

-លោក **ផុន ពុធបូរី**


# មាតិកា


- គោលដៅយុទ្ធសាស្ត្រ៤ និងវិស័យអាទិភាព៤...............០១

- យេនឌ័រក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣....០២

-អបអរសាទរខួបលើកទី១០៣ ទិវាអន្តរជាតិនារី ៨មីនា...០៣

-គណៈប្រតិភូ កកន ថតរូបអនុស្សាវរីយ៍........................០៤

-លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី.........................០៥

-វេទិកាយុវវ័យជជែកពិភាក្សា........................................០៦

-យុទ្ធនារីកងទ័ពមួកខៀវ............................................០៧

-សុន្ទរកថាលោកជំទាវ ម៉ែន សំអន..............................០៨

-សុន្ទរកថាលោកជំទាវវេជ្ជ,រដ្ឋមន្ត្រីក្រសួងកិច្ចការនារី......១២

-សេចក្តីជូនដំណឹងលទ្ធផលនៃកិច្ចប្រជុំក្រុម..................១៤

-វីរនារី ស៊ិន សៀវម៉ី....................................................១៧

-លទ្ធផលសម្រេចបាន ស្ត្រីចូលរួមក្នុងវិស័យ.................១៨

-ពិធីស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការរបស់..................២០

-សកម្មភាពសំខាន់ៗរបស់ថ្នាក់ដឹកនាំ កកន...................២១

-ការអប់រំដើម្បីសមភាពយេនឌ័រ..................................២២

-សកម្មភាពទប់ស្កាត់អំពើហិង្សាលើស្ត្រី........................២៣

-ខ្លួនពិការតែចិត្តមិនពិការ..........................................២៤



**ការិយាល័យនិពន្ធ**

**នាយកដ្ឋានព័ត៌មាន ក្រសួងកិច្ចការនារី ផ្លូវត្រុងមាន់ ភូមិដំណាក់ធំIII សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ**

Editorial Office : Information Department, Ministry of Women's Affairs

Street Trung Meann,Phum DamNakThom III, S.K. Steng MeanChey, Khan MeanChey, Phnom Penh, Cambodia. Tel: 023 880 737

# គោលដៅយុទ្ធសាស្ត្រ ៤ និងវិស័យអាទិភាព ៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

*នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ បានបើកសម័យប្រជុំដំបូងរបស់ខ្លួននៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** *។ នៅក្នុងសម័យប្រជុំនេះ សម្តេចតេជោនាយករដ្ឋមន្ត្រីបានប្រកាសចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តការងារ និងកសាងមាតុភូមិឆ្ពោះទៅរកអនាគតដ៏រុងរឿង ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជន ដែលបានសម្តែងចេញតាមរយៈការបោះឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ រាជរដ្ឋាភិបាលបានលើកឡើងនូវគោលដៅយុទ្ធសាស្ត្រ ៤ និងវិស័យអាទិភាព ៤ ដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោម:*

## គោលដៅយុទ្ធសាស្ត្រ ៤:

**ទី១-** ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាប អាចគ្រប់គ្រងបានអត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។

**ទី២-** បង្កើតការងារឱ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជនពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការទាក់ទាញ និងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស។

**ទី៣-** សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១% ក្នុងមួយឆ្នាំ ក៏ដូចជា គោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុង " គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា " ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

**ទី៤-** បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

## វិស័យអាទិភាពទី ៤:

**ទី១-**ការអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ ដែលកាន់តែបើកចំហរ តាមរយៈ (១). ការបណ្តុះបណ្តាលពលករឱ្យមានជំនាញ និងផលិតភាពខ្ពស់តាមសេចក្តីត្រូវការនៃទីផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ (២). ការរៀបចំក្របខណ្ឌគតិយុត្តិ និងកសាងស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឆ្លើយតបទៅនឹងចំណុចទី១ ខាងលើ (៣). ការលើកទឹកចិត្តវិស័យឯកជនឱ្យចូលរួមនៅក្នុងកិច្ចការនេះនិង (៤). ការពង្រឹងគុណភាពនៃការអប់រំ និងការលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ។

**ទី២-** ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីកសាងប្រព័ន្ធឡូជិស្ទិកដ៏រស់រវើក តាមរយៈការសាងសង់បណ្តាញដឹកជញ្ជូនពហុសណ្ឋាន ក្នុងគោលដៅធានាឱ្យបាននូវការតភ្ជាប់ផ្ទៃក្នុងប្រទេស និងការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ព្រមទាំងឆ្លើយតបបានទៅនឹងការរីកចម្រើន ផ្នែកនគរូបនីយកម្ម ដែលនឹងនាំមកនូវ (១).ការកាត់បន្ថយថ្លៃដឹកជញ្ជូន (២).ការបង្កើនភាពអាចទុកចិត្តបាន និងភាពស័ក្តិសិទ្ធិ (៣).ការពង្រឹងភាពប្រកួតប្រជែង និង(៤).ការបង្កើនការវិនិយោគ និងពាណិជ្ជកម្ម។ ម្យ៉ាងវិញទៀតរាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពក្នុងការពង្រីកសមត្ថភាពផលិត និងផ្គត់ផ្គង់ថាមពលពីប្រភពដែលមានតម្លៃកាន់តែទាប និងពង្រីកបណ្តាញចែកចាយ សំដៅធានាសន្តិសុខថាមពល ភាពអាចទុកចិត្តបានក្នុងការផ្គត់ផ្គង់ថាមពល ព្រមទាំងថ្លៃសមរម្យ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ នៃការអភិវឌ្ឍ ។

**ទី៣-**ការបន្តអភិវឌ្ឍ និងបង្កើនតម្លៃបន្ថែម នៃវិស័យកសិកម្មតាមរយៈ (១).ការបង្កើនតម្លៃបន្ថែមនៃការផលិត និងការនាំចេញអង្ករពិសេស ការផ្តោតលើអង្ករក្រអូប អង្ករសរីរាង្គ និងកសិផលមានតម្លៃខ្ពស់ឯទៀត ដូចជា កៅស៊ូ ស្វាយចន្ទី ពោត សណ្តែកបាយ ល្ង ម្រេច ស្ករត្នោត ផ្លែឈើ កាហ្វេ បន្លែបង្ការ និង ផ្កាជាដើម (២).ការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្មដែលទីផ្សារត្រូវការ ដូចជា សាច់ ត្រី ផលិតផលទឹកដោះគោជាដើម (៣).ការជំរុញលើកទឹកចិត្ត ដល់ការវិនិយោគក្នុងវិស័យកសិឧស្សាហកម្ម និង(៤).ការបង្កើនផលិតភាពទំនើបកម្មកសិកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

**ទី៤-** ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ តាមរយៈ (១).ការបន្តការអនុវត្តកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ សុចរិតភាព តម្លាភាព និងគណនេយ្យភាព (២).ការបន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យ ដើម្បីបង្វិតសេវាសាធារណៈឱ្យជិតប្រជាជន លើកកម្ពស់កិច្ចដំណើរការប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងធានាបាននូវតុល្យភាពក្នុងការអនុវត្តអំណាច (៣).ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាប្រសិទ្ធភាពក្នុងការវិភាជ និងការប្រើប្រាស់ថវិកា និង (៤).ការបង្កើនការទាក់ទាញចំពោះការវិនិយោគ ក្នុងនោះមានការកាត់បន្ថយថ្លៃដើម និងរបាំងធុរកិច្ច ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តដល់ការវិនិយោគ ការពង្រឹងភាពជឿទុកចិត្ត និងភាពអាចប៉ាន់ប្រមាណបានក្នុងការធ្វើធុរកិច្ច ព្រមទាំងការផ្តោតការយកចិត្តទុកដាក់លើកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស៕.

# យេនឌ័រក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

រាជរដ្ឋាភិបាលនីតិកាលទី៥ នឹងផ្ដោតការយកចិត្តទុកដាក់ទៅលើការបន្តពង្រឹងការគ្រប់គ្រងជីវភាពប្រជាសាស្ត្រសំដៅធានាបង្កើនគុណភាព " **មូលធនមនុស្ស** " ដែលជាគន្លឹះកំណត់ភាពប្រកួតប្រជែងរយៈពេលវែងរបស់ប្រទេស ដើម្បីទាញយកផលប្រយោជន៍ និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្ដានុពលប្រជាសាស្ត្ររបស់កម្ពុជាសម្រាប់ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងវឌ្ឍនភាព និងវិបុលភាពរបស់ប្រជាជន។ លើមូលដ្ឋាននេះរាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើះ

**ទី១-** ការរៀបចំគោលនយោបាយគ្រប់គ្រងចលនាបន្លាស់ទីរបស់ប្រជាជន គួបផ្សំនឹងការពង្រឹង ការងាររៀបចំដែនដី និងនគរូបនីយកម្មដោយផ្ដោតលើ :

(១). ការអភិវឌ្ឍរាជធានីភ្នំពេញ, ប៉ូលសេដ្ឋកិច្ចសំខាន់ៗនៅក្នុងប្រទេស, ក្រុងរណប និងតំបន់ទីប្រជុំជនទទ្ទឹម នឹងការបង្កើតការងារនៅតាមមូលដ្ឋាន និង

(២). ការតភ្ជាប់ក្រុងរណប និងតំបន់ទីប្រជុំជនទៅនឹងប៉ូលសេដ្ឋកិច្ចសំខាន់ៗឱ្យក្លាយជារបៀងសេដ្ឋកិច្ច។

**ទី២-** ការបន្តអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព, សមត្ថភាព និងគុណធម៌ តាមរយៈការអនុវត្តវិធានការចម្រុះប្រទាក់ក្រឡាក្នុងវិស័យពាក់ព័ន្ធជាអាទិ៍ អប់រំ, ស្រាវជ្រាវ, វិទ្យាសាស្ត្រ, បច្ចេកវិទ្យា, បណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ និងសុខាភិបាល។

**ទី៣-** ការបន្តលើកកម្ពស់តួនាទីរបស់ស្ត្រី និងយុវជនក្នុងវិស័យសេដ្ឋកិច្ចតាមរយៈការពង្រីកកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ, ការបំពាក់បំប៉ន់ជំនាញបច្ចេកទេស និងសហគ្រិនភាព ព្រមទាំងការពង្រឹងភាពអង់អាចរបស់ស្ត្រី និងយុវជន។

**ទី៤-** ការបន្តលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យសាធារណៈ តាមរយៈការបង្កើនសមាមាត្រ និងការពង្រឹងសមត្ថភាពស្ត្រីនៅក្នុងជួរថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ទាំងកម្រិតនយោបាយ ទាំងកម្រិតជំនាញ។

**ទី៥-** ការបន្តជំរុញអនុវត្ត " **ផែនការសកម្មភាពជាតិ ស្ដីពី ការទប់ស្កាត់អំពើហិង្សាលើស្ត្រី** " សំដៅលុបបំបាត់ឥរិយាបថប្រើអំពើហិង្សាលើស្ត្រី និងពង្រីកវប្បធម៌អហិង្សាដើម្បីរួមចំណែកលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក៏ដូចជា កសាងគ្រួសារមានសុភមង្គល សហគមន៍ និងសង្គមជាតិសុខដុមរមនា។

**ទី៦-** ការបន្តពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទទៅលើស្ត្រី និងកុមារ។

**ទី៧-** ការបន្តលើកកម្ពស់សុខុមាលភាព និងសិទ្ធិរបស់កុមារ ដែលមានកំណត់ក្នុងអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមាររួមមានសិទ្ធិរស់រានមានជីវិត, សិទ្ធិទទួលបានការអភិវឌ្ឍ, សិទ្ធិទទួលបានការការពារនិងសិទ្ធិចូលរួមរបស់កុមារ។

**ទី៨-** ការបន្តយកចិត្តទុកដាក់បង្កើតលក្ខខណ្ឌឱ្យយុវជនដែលជាកម្លាំងបន្តវេនអាចចូលរួមក្នុងការដឹកនាំនិងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងការការពាររាល់សមិទ្ធផលសង្គម តាមរយៈការជំរុញការអនុវត្តជាជំហានៗ នូវទិសដៅយុវភាវូបនីយកម្មក្នុងការផ្ដល់ការទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់។

**ទី៩-** ការបន្តជំរុញការបញ្ជ្រាបយេនឌ័រនិងសេចក្ដីត្រូវការរបស់យុវជនទៅក្នុងគោលនយោបាយនិងផែនការអភិវឌ្ឍគ្រប់វិស័យនិងគ្រប់កម្រិត។

# អបអរសាទរ ខួបលើកទី ១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤




លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីអបអរសាទរខួបទី១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ លើប្រធានបទ " សមភាព នៃការអប់រំ មានសារៈសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម " នៅវិទ្យាស្ថានជាតិអប់រំដែលរៀបចំដោយក្រសួងកិច្ចការនារី (កកន) កាលពីថ្ងៃទី ៨ ខែមីនា ឆ្នាំ២០១៤ កន្លងទៅនេះ។





## គណៈប្រតិភូ កកន ថតរូបអនុស្សាវរីយ៍ ជាមួយ ឯកឧត្តម ទេព ងន ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរ ខួបលើកទី ១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ នៅវិមានចំការមន



## គណៈប្រតិភូ ក្រសួងកិច្ចការនារី ថតរូបអនុស្សាវរីយ៍ ជាមួយឯកឧត្តម ងួន ញ៉ិល ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរ ខួបលើកទី ១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ នៅវិមានរដ្ឋសភា





លោកជំទាវវេជ្ជ, **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាអធិបតីក្នុងពិធីអបអរសាទរខួបទី១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ នៅខណ្ឌដង្កោ។

---

លោកជំទាវវេជ្ជ, **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាវាគ្មិនក្នុងវេទិកាតុមូលជាមួយស្ត្រី ស្តីពី " សមភាព នៃការអប់រំមានសារៈសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម " នៅស្ថាននីយ៍ទូរទស្សន៍ជាតិកម្ពុជា





លោកជំទាវវេជ្ជ, **អ៊ឹង កន្ថាផាវី** ថតរូបអនុស្សាវរីយ៍ជាមួយអ្នកចូលរួម

# វេទិកាយុវជ័យជជែកពិភាក្សាស្តីពី សមភាពយេនឌ័រ ដើម្បីអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០១៤



លោកជំទាវ **កុប ម៉ារីយ:** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាអធិបតីក្នុងវេទិកា យុវវ័យជជែកពិភាក្សា នៅទីស្តីការ ក្រសួងកិច្ចការនារី



គណៈអធិបតីថតរូបអនុស្សាវរីយ៍ ជាមួយនិស្សិតសាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិ ក្នុងវេទិកា យុវវ័យជជែកពិភាក្សា នៅ ស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា

## កម្មវិធីយុវជនជ័យឆ្លាត ដើម្បីអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០១៤







ឯកឧត្តម **ប៉ាវ ហមផាន** អភិបាលនៃគណៈអភិបាលខេត្តរតនគីរី ចូលរួមជាអធិបតីក្នុងពិធីអបអរសាទរខួបទី១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ រៀបចំដោយមន្ទីរកិច្ចការនារី ខេត្តរតនៈគីរី

## យុទ្ធនារីកងទ័ពមួកខៀវកម្ពុជាប្រារព្ធខួបទី១០៣ ទិវាអន្តរជាតិនារី ៨ មីនា

យុទ្ធនារីកងទ័ពមួកខៀវកម្ពុជា បានប្រារព្ធខួបទី១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាពបោសសម្អាតមីន និងកាកសំណល់សង្គ្រាម ដោយទទួលបានការកោតសរសើរស្នាដៃការងារពីសហគមន៍អន្តរជាតិ តាមរយៈការបំពេញដោយជោគជ័យបេសកកម្មរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ។



គណៈអធិបតីថតរូបអនុស្សាវរីយ៍ជាមួយយុទ្ធនារីកងទ័ពមួកខៀវកម្ពុជា

ព្រឹត្តិបត្រនារីរតនៈសូមធ្វើការកែតម្រូវ នូវព្រឹត្តិបត្រលេខពិសេសឆ្នាំទី៨ ត្រង់ទំព័រទី២៦ ស្ថិតិយេនឌ័រសំខាន់ៗក្នុងប្រទេសកម្ពុជា ផ្នែកព័ត៌មានរដ្ឋបាល (ចំនួនប្រជាពលរដ្ឋ) ស្ត្រី ១,៥៥៥,០៨៣ ទៅជា ៧,៥៥៥,០៨៣ វិញ ។ សូមអរគុណ !

សុន្ទរកថា

លោកជំទាវ **ម៉ែន សំអន**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីរំលឹកខួបលើកទី១០៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៤

**នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៤**

*******

*-លោកជំទាវ ឯកឧត្តម*

*-អ្នកអង្គម្ចាស់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិត !*

ក្នុងនាម ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងជំនួសមុខឲ្យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសំដែងនូវមោទនភាពនិងរីករាយជាទីបំផុត ដែលបានមកចូលរួមប្រារព្ធ **ទិវាអន្តរជាតិនារី ៨មីនា ខួបទី១០៣ ឆ្នាំ២០១៤** នៅក្នុងព្រឹកនាថ្ងៃនេះ ជាមួយ លោកជំទាវ ឯកឧត្តម អ្នកអង្គម្ចាស់ អ្នកឧកញ៉ា លោកឧកញ៉ា លោកស្រី អស់លោក សមាជិក សមាជិកា នៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ និងក្មួយៗនិស្សិតទាំងអស់ នៅទីនេះ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងកោតសរសើរខ្ពស់ ចំពោះការប្រារព្ធទិវានៅថ្ងៃនេះ ដែលរៀបចំឡើង ដើម្បីលើកនូវការទទួលស្គាល់ ព្រមទាំងរំលឹកឡើងវិញ នូវការតស៊ូដ៏ស្វិតស្វាញ ក្នុងការជំនះរាល់ឧបសគ្គ ដែលរាំងស្ទះការលើកស្ទួយ លើកកម្ពស់សិទ្ធិ នារី និងជីវភាពរស់នៅរបស់ស្ត្រីកម្ពុជា ក៏ដូចជាស្ត្រីនៅទូទាំងសកលលោក និងការប្តេជ្ញា រួមគ្នាតទៅមុខទៀត ដើម្បីសម្រេចបាននូវបំណងប្រាថ្នានេះ។

លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះ បានបង្កើតឡើងនូវលទ្ធផលល្អប្រសើរចំពោះស្ត្រីឲ្យទទួលបាននូវការទទួលស្គាល់សមភាព រវាងស្ត្រីនិងបុរស ក្នុងគ្រប់វិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងទទួលបានសិទ្ធិ និងសេរីភាពពេញលេញក្នុងតម្លៃជាមនុស្សជាតិ និងជាពលរដ្ឋរបស់ប្រទេស ដើម្បី ចូលរួមចំណែកដោយស្មើភាព និងក្នុងភាពជាដៃគូមិនអាចខ្វះបានជាមួយបុរស ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។

ប្រធានបទ សម្រាប់ទិវាអន្តរជាតិនារី៨មីនានៅឆ្នាំនេះ គឺ៖ **សមភាពនៃការអប់រំ មានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍សង្គម** ក្នុងគោលបំណងជំរុញឲ្យមានការផ្តល់ឱកាសឲ្យបុរស ស្ត្រី យុវវ័យ ទទួលបានចំណេះដឹង ជំនាញ និងមានសីលធម៌ ដើម្បីក្លាយជាធនធានដ៏ល្អ មានសក្តានុពល សម្រាប់ពន្លឿនការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិ ពិតជាមានអត្ថន័យ និងសារៈសំខាន់ណាស់ សមស្របទៅនឹងបរិបទ នៃសហគមន៍អាស៊ាន ដែលត្រូវការជាចាំបាច់នូវធនធានមនុស្ស ប្រកបដោយគុណសម្បត្តិ ដើម្បីធ្វើឲ្យកម្ពុជាមាន លក្ខណៈប្រកួតប្រជែងនៅក្នុងតំបន់ និងនៅក្នុងពិភពលោក។

*-លោកជំទាវ ឯកឧត្តម*

*-អ្នកអង្គម្ចាស់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិត !*

ខ្ញុំសូមអបអរសាទរ ចំពោះលទ្ធផលសម្រេចបានគួរឲ្យកត់សំគាល់ ដែលលោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ច-ការនារីបានលើកឡើងនេះ។ នេះជាកិច្ចខិតខំប្រឹងប្រែងរួមគ្នា ឆ្ពោះទៅកសាងប្រទេសកម្ពុជាមួយមានសន្តិភាព ស្ថិរភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍លោនឡើង ដែលផ្តើមចេញពីធនធានមនុស្សប្រកបដោយគុណវឌ្ឍន៍ ។

ដូចដែលអង្គពិធីបានជ្រាបរួចមកហើយ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ គឺជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ និងការប្រកួតប្រជែងក្នុងកម្រិតតំបន់ និងពិភពលោក។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានជំរុញការកសាងសមត្ថភាពធនធានមនុស្សឲ្យដល់កម្រិតខ្ពស់ ដូចជា ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ការច្នៃប្រឌិតបច្ចេកទេស ជំនាញ បច្ចេកទេស វិជ្ជាជីវៈកម្រិតខ្ពស់ ការគ្រប់គ្រងហិរញ្ញវត្ថុ ជំនាញ រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេសផង ដើម្បីរួមចំណែកឈានទៅសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យម កម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។

ជាការពិត គោលការណ៍សមភាពក្នុងការអប់រំ មានចែងនៅក្នុងមាត្រា ៦៦ នៃរដ្ឋធម្មនុញ្ញ ដែលធានាឱ្យប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិស្មើគ្នា ក្នុងការទទួលការអប់រំកម្រិតបឋម និងមធ្យមសិក្សានៅ សាលារៀនសាធារណៈ យ៉ាងតិចប្រាំបួនឆ្នាំ ដោយឥតបង់ថ្លៃ ដោយរាជរដ្ឋាភិបាលបានបង្កលក្ខណៈងាយស្រួល ដល់កុមារី កុមារ យុវជន និងយុវនារីកម្ពុជាឱ្យមានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំ ប្រកបដោយគុណភាព ដោយមិនប្រកាន់ពីស្ថានភាព ភេទ ឬពិការភាព និងបានកាត់បន្ថយគម្លាតយេនឌ័រនៅគ្រប់កម្រិត ដោយបានបង្កើនចំនួនអាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រ ពិសេសនារី បង្កើនចំនួនគ្រឹះស្ថានអប់រំសាធារណៈ ដល់មូលដ្ឋាន បង្កើតអន្តេវាសិកដ្ឋាន សម្រាប់សិស្សស្រីស្នាក់នៅជាដើម។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ចំពោះក្រុមជនងាយរងគ្រោះ ពិសេសស្ត្រី និងកុមារ ដោយបានពង្រឹង និងពង្រីកជាបន្តបន្ទាប់នូវស្មារតីសាមគ្គីប្រជាជាតិជាធ្លុងមួយ និងការអភិវឌ្ឍន៍ធនធានមនុស្ស ដោយគ្មានការរើសអើងតាមរយៈការអនុម័ត និងពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ គោលនយោបាយស្តីពីការអប់រំកុមារពិការជាដើម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ តាមរយៈការអភិវឌ្ឍន៍គោលនយោបាយចំពោះមនុស្សចាស់ជរាទីពឹង និងជនជាតិដើមភាគតិចផងដែរ។

ចំពោះយុវជន រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជនកម្ពុជា សំដៅ អភិវឌ្ឍទាំងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទា និងសីលធម៌ឱ្យក្លាយទៅជា "មូលធនមនុស្ស" ប្រកបដោយសក្តានុពល និងផ្តល់ឱកាសឱ្យចូលរួមក្នុងការធ្វើសេចក្តីសម្រេច ក៏ដូចជាក្នុងការអភិវឌ្ឍន៍គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។ ជាក់ស្តែង យុវជនបានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងកិច្ចការសង្គម ផ្សេងៗតាមរយៈ ចលនាកាយរឹទ្ធិ យុវជនកាកបាទក្រហម យុវជនស្ម័គ្រចិត្តក្នុងការអនុវត្ត "គោលនយោបាយចាស់ សកម្មភាពថ្មី លើវិស័យដីធ្លី" ព្រមទាំងចលនាយុវជន ក្នុងការលើកតម្កើងវប្បធម៌ ប្រពៃណី អត្តសញ្ញាណជាតិ និងក្នុងកិច្ចការការពារបរិស្ថាន សំដៅប្រែក្លាយយុវជនឱ្យក្លាយទៅជាកម្លាំងចលករដ៏មាន សារៈសំខាន់ សម្រាប់ការអភិវឌ្ឍន៍លើគ្រប់វិស័យ។

លើផ្នែកសុខុមាលភាព និងសុវត្ថិភាពសង្គម នៅព្រះរាជាណាចក្រកម្ពុជា រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ អំពើជួញដូរ អំពើហិង្សាផ្លូវភេទ និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់នារី គឺជាអំពើខុសច្បាប់ ត្រូវបានហាមឃាត់និងទប់ស្កាត់ ដោយរាជរដ្ឋាភិបាលបាន និងកំពុងជំរុញ ការអនុវត្តន៍ច្បាប់ដែលពាក់ព័ន្ធ គោលនយោបាយភូមិឃុំមានសុវត្ថិភាព និងបានដាក់ទោសទណ្ឌ ដល់ជនល្មើសដែលធ្វើអំពើហិង្សាលើស្ត្រី ធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរស្ត្រី រំលោភបំពានកម្លាំងពលកម្ម និងការងារទាំងឡាយណាធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាព និងភាពសុខដុមរមនាក្នុងសង្គមគ្រួសារ និង សង្គមជាតិ។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា បានបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលបានចាត់ទុកស្ត្រីជា *ឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ* ដោយបន្តអនុវត្តគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រនៅគ្រប់វិស័យ ដូចជាបានជំរុញក្រសួង ស្ថាប័នពាក់ព័ន្ធឱ្យធ្វើការងារ ផ្តោតលើការពង្រីក ភាពជាដៃគូសេដ្ឋកិច្ចរបស់ស្ត្រី តាមរយៈការអភិវឌ្ឍន៍សមត្ថភាពលើផ្នែកចំណេះដឹង ជំនាញ វិជ្ជាជីវៈ ក្នុងការទទួលបានសេវាឥណទានខ្នាតតូច និងមធ្យម និងការបង្កើនលទ្ធភាពឱ្យស្ត្រីក្លាយជាសហគ្រិន។

រយៈកាលកន្លងមក រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជំរុញការអនុវត្តន៍យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍសេដ្ឋកិច្ចសង្គម ការពង្រីកលទ្ធភាពរបស់ស្ត្រី និងកុមារីនៅជនបទ ឱ្យទទួលបានឱកាសចូលរៀននៅកម្រិត បឋមសិក្សា មធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការធានាការទទួល បានសេវាសុខាភិបាលប្រកបដោយគុណភាព ទាន់ពេលវេលា ក្នុងតម្លៃសមរម្យ និងការផ្តល់នូវកិច្ចការពារ ផ្លូវច្បាប់ដល់ជនរងគ្រោះជាស្ត្រីទៀតផង។

ចំណែកវិស័យនយោបាយ និងតួនាទីធ្វើសេចក្តីសម្រេច ដូចដែលលោកជំទាវជួបមន្ត្រីបានរៀបរាប់រួចមកហើយ ស្ត្រីបានកើនឡើងនៅគ្រប់ស្ថាប័ន និងគ្រប់កម្រិតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងឆ្នាំ២០១៣នេះ នៅថ្នាក់ជាតិរដ្ឋមន្ត្រីជាស្ត្រីមាន ៣រូប (១០.៧%) រដ្ឋលេខាធិការជាស្ត្រីបានកើនឡើង ពីឆ្នាំ២០០៨-២០១៣ ពី ១៦រូប (៨%) ទៅ

៣៧រូប (២០.៥៩%) ហើយក្នុងនោះចំនួនស្ត្រីជាអនុរដ្ឋលេខាធិការ កើនឡើងពី ៣៧រូប (១៥.១%) ទៅ ៤៧រូប (១៧.៥៩%)។ រីឯការតែងតាំងស្ត្រីជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ឃុំសង្កាត់ គិតចាប់ពីឆ្នាំ២០០៧ ដល់ ឆ្នាំ២០១២ បានកើន ឡើងពី១៥.១% ទៅ១៧.៧៥%។

*-លោកជំទាវ ឯកឧត្តម*

*-អ្នកអង្គម្ចាស់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងក្មួយៗទាំងអស់ !*

ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកម្ពុជា នៅតែជាបញ្ហាប្រឈមមួយរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលនឹងបន្តផ្តោតអាទិភាពលើការពង្រឹងគុណភាព ការអាចឆ្លើយតបទៅនឹងតម្រូវការ នៃទីផ្សារពលកម្ម និងការអភិវឌ្ឍន៍ជំនាញបច្ចេកទេសខ្ពស់សម្រាប់យុវជន ដើម្បីបង្កើនឱកាសទទួលបានការងារ និងប្រើប្រាស់ ឱ្យអស់សក្តានុពលនូវផលលាភប្រជាសាស្ត្ររបស់កម្ពុជា ក៏ដូចជាដើម្បីធានាការបន្តវេន ក្នុងការដឹកនាំនិងអភិវឌ្ឍប្រទេសជាតិ។ ទន្ទឹមនឹងការកសាងធនធានមនុស្ស វិស័យសុខាភិបាលក៏នៅតែមានបញ្ហាប្រឈមផងដែរ ដែលរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដោះស្រាយ គឺការលើកកម្ពស់អនាម័យ ការកែលម្អស្ថានភាពអាហារូបត្ថម្ភ ប្រកបដោយប្រសិទ្ធភាព ការផ្តល់សេវាសុខភាព ដោយគ្មានការរើសអើង និងការធានាថ្លៃសមរម្យ ស្របជាមួយនឹងការលើកកម្ពស់សមភាពយេនឌ័រផងដែរ។

ជាមួយគ្នានេះផងដែរ បញ្ហាអំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចផ្លូវភេទ អំពើជួញដូរ និងអំពើថ្មី អាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ បញ្ហាគ្រឿងញៀន និងភាពក្រីក្រជាដើម នៅតែជាកង្វល់ចំពោះមុខ របស់យើងនៅឡើយ។ បញ្ហាទាំងអស់នេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែង ពុះពារ ជំនះ និងដោះស្រាយដោយស្វាហាប់ ក្លាហាន និងកាន់តែមាន

៦

ប្រសិទ្ធភាពថែមទៀត ដើម្បីឱ្យប្រជាជនយើង ជាពិសេសស្ត្រីកម្ពុជាដែលមានចំនួនរហូតដល់ ៥២ភាគរយ នៃប្រជាជនសរុប អាចមានភាពជាដៃគូ ពេញលេញ សម្រាប់រួមចំណែកនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់យើង។

ឆ្លៀតក្នុងឱកាសនៃ **ទិវានារីអន្តរជាតិ ៨មីនា ឆ្នាំ២០១៤** នេះ ខ្ញុំសូមអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់រូប ដល់ក្រសួងស្ថាប័នជាតិ ផ្នែកឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងគណបក្សនយោបាយ ទាំងអស់ ៖

១-សូមជួយបង្កលក្ខណៈ ឱ្យស្ត្រីបំពេញតួនាទី ជាភ្នាក់ងារបង្កើតសុខដុមរមនាក្នុងសង្គមគ្រួសារ និងសង្គមជាតិ និងសូមឱ្យបុរសចូលរួមចំណែកជាមួយស្ត្រីថែរក្សាសន្តិភាព ស្ថេរភាព សណ្តាប់ធ្នាប់សាធារណៈ និងជៀសវាងការបង្កអស្ថេរភាពសង្គម ដើម្បីភាពចម្រើនរុងរឿងក្នុងជីវិតគ្រួសាររបស់ខ្លួន និងការរីកចម្រើនរបស់ប្រទេសជាតិ។

២. សូមមាតា បិតាជួយអប់រំកូនចៅ តាមគោលការណ៍នៃព្រហ្មវិហារធម៌ រួមទាំងសីលធម៌ សុជីវធម៌ និងផ្តល់ឱកាសឱ្យកូនប្រុស កូនស្រីរៀនបានស្មើគ្នាដល់កម្រិតឧត្តមសិក្សា ដើម្បីធ្វើឱ្យគ្រួសារ និងសង្គមមានភាព ថ្លៃថ្នូរ សុខដុមរមនា និងចម្រើនរុងរឿង។

៣. សូមស្ត្រីទាំងអស់ ត្រូវប្រកាន់ខ្ជាប់ ភាពថ្លៃថ្នូរ និងកិត្តិយស ជាស្ត្រីខ្មែរបានល្អ និងមានសីលធម៌រស់នៅស្អាតស្អំ មានចរិយាសុភាព រាបសារ តែម៉ឺងម៉ាត់។

៤. សូមស្ត្រីទាំងអស់ខិតខំបង្កើនសមត្ថភាពជំនាញ ដើម្បីកសាងខ្លួនទៅអនាគត និងមិនត្រូវបណ្តែតបណ្តោយ ឱ្យពេលវេលាកន្លងទៅ ដោយគ្មានបានការ នោះទេ។

៥. សូមគ្រប់គណបក្សនយោបាយ គោរព និងអនុវត្តតាមបទបញ្ញត្តិមាត្រា ១២នៃច្បាប់ស្តីពីការបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលធានាឱ្យមានបេក្ខនារីចូលរួម និងមានឈ្មោះ នៅលំដាប់លេខរៀងសមស្របក្នុងបញ្ជីបេក្ខជន ដើម្បីបង្កើនចំនួនស្ត្រីឱ្យបានកាន់តែច្រើនថែមទៀត។

៦. សូមមជ្ឈដ្ឋានបន្តលើកកម្ពស់សិទ្ធិ ស្ថានភាព និងផ្តល់ការអប់រំដល់ស្ត្រីពិការ និងជនជាតិភាគតិច ដោយគ្មានការរើសអើង ដើម្បីបានទទួលចំណេះដឹង ជំនាញ វិជ្ជាជីវៈ សម្រាប់ប្រកបមុខរបរបង្កើនប្រាក់ចំណូលក្នុង គ្រួសារ។

៧. សូមក្មួយៗយុវជន យុវនារីទាំងអស់បន្តខិតខំរៀនសូត្រ និងប្រកាន់ខ្ជាប់នូវសីលធម៌ ដើម្បីក្លាយជា មូលធនមនុស្សដ៏មានសក្តានុពល ក្នុងការរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ ដោយជៀសវាងការប្រើប្រាស់ចំណេះដឹង និងបច្ចេកវិទ្យាខុសទិសដៅ ដែលអាចបង្កឱ្យមានអំពើហិង្សា ភាពចលាចល នាំមកនូវ អសុវត្ថិភាពសង្គម។ សូមប្អូនៗ និងក្មួយៗ ប្រែក្លាយចំណេះដឹង មុខជំនាញ និងបទពិសោធន៍ទាំងឡាយ ឱ្យក្លាយទៅជាឧត្តមប្រយោជន៍ខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

*-លោកជំទាវ ឯកឧត្តម*

*-អ្នកអង្គម្ចាស់ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី និងក្មួយៗទាំងអស់ !*

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរ និងអរគុណដល់ក្រសួងកិច្ចការនារី ក្រសួង ស្ថាប័នជាតិ ផ្នែកឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិទាំងអស់ដែលបានធ្វើការងារ និងចូលរួមគាំទ្រការ លើកកម្ពស់ស្ថានភាព ឋានៈ តួនាទី សេចក្តីថ្លៃថ្នូររបស់ស្ត្រី ជាពិសេសបានសហការ និងគាំទ្រដល់ **ទិវាអន្តរជាតិ នារី ៨មីនា ឆ្នាំ២០១៤** នេះ និងសូមបន្ថែមចំណែកប្រែក្លាយខ្លឹមសារនៃប្រធានបទ "សមភាពនៃការអប់រំមានសារៈសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម" ឱ្យទៅជាសកម្មភាពជាក់ស្តែង ដើម្បីសង្គមកម្ពុជាសម្រេចបាននូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ជាទីបញ្ចប់ ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនៃ **ខួបទី ១០៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤** នេះ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទូទាំងប្រទេស ខ្ញុំសូមឧទ្ទិសថ្វាយ ជូនព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ អតីតព្រះមហាវីរក្សត្រ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ នូវព្រះកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទិគុណដ៏ធំធេង លើសលប់ចំពោះស្នាព្រះហស្ថ ជាមរតកដ៏មានតម្លៃមិនអាចកាត់ថ្លៃបានសម្រាប់កូនចៅ និងចៅទួតរបស់ព្រះអង្គ។ ទូលព្រះបង្គំខ្ញុំ ព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរជ័យសិរីមង្គល បវរមហាប្រសើរថ្វាយ **សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមថ្វាយព្រះពរ ព្រះករុណា **ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមគុណបុណ្យព្រះរតនត្រ័យ ទេវតារក្សាព្រះមហាស្វេតច្ឆត្រ គេជៈបារមី នៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ និងវត្ថុស័ក្តិសិទ្ធិដែលរក្សាព្រះរាជាណាចក្រកម្ពុជា សូមតាមជួយគ្រាប់គ្រង ថែរក្សាព្រះអង្គ និងសូមបានប្រកបដោយព្រះរាជសុខភាពបរិបូណ៌ ព្រះពលំមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បី ព្រះអង្គគង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រគ្រប់រូបរបស់ព្រះអង្គ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមជូនពរលោកជំទាវ ឯកឧត្តម អ្នកអង្គម្ចាស់ លោកឧកញ៉ា អ្នកឧកញ៉ា លោក លោកស្រី ក្មួយៗ និងភ្ញៀវជាតិ អន្តរជាតិ និងសូមមានសុខភាពល្អបរិបូណ៌ ទទួលបាននូវជោគជ័យ ក្នុងគ្រប់ភារកិច្ច និង សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ *អាយុ វណ្ណៈ សុខៈ ពលៈ* កុំបី ឃ្លៀងឃ្លាត ឡើយ។ សូមអរគុណ !

[illegible]

Oxfam, BMZ [illegible], GIZ, DFAT [illegible], UNDP, UNFPA, EWMI [illegible], USAID, PyD, AECID [illegible], JICA, ActionAid, Plan International, UKAID [illegible], Somaly Mam Foundation, UNIAP, CDRI, Care Cambodia, NGO's Forum, Heifer International, [illegible] AFESIP, Seed Garment (Cambodia) Co.,Ltd, United Pharma (Cambodia) [illegible] Smart ។

[illegible]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:** ៥៦៤ សជណ.សវ

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៤*

## សេចក្តីជូនដំណឹង

## លទ្ធផលនៃកិច្ចប្រជុំបូកសរុបសកម្មភាពការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ប្រចាំឆ្នាំ២០១៣ និងផែនការសកម្មភាពការងារឆ្នាំ២០១៤ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤

កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង ៨:៣០ព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំបូកសរុបសកម្មភាពការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីឆ្នាំ២០១៣ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

ក្រោយពីបានស្តាប់ និងឯកភាពលើរបាយការណ៍បូកសរុបសកម្មភាពការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីឆ្នាំ២០១៣ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១៤រួចមក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានថ្លែងសំណេះសំណាល និងបានណែនាំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បន្តអនុវត្តនូវអនុសាសន៍ទាំង១៦ចំណុច ដែលបានអនុវត្តក្នុងឆ្នាំ២០១៣កន្លងមក ដើម្បីពង្រឹងការអនុវត្តការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ឆ្នាំ២០១៤ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់៖

១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តអនុវត្តព្រះរាជានុសាសន៍ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី** ក្នុងការផ្សព្វផ្សាយអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ( ស៊ី-ដ ) និងឯកសារពាក់ព័ន្ធឱ្យបានទូលំទូលាយ រហូតដល់កម្រិតថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងបន្តចុះតាមដានការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីលើកអនុសាសន៍ជូនរាជរដ្ឋាភិបាល។

២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តចុះស្រាវជ្រាវអំពីស្ថានភាពរបស់ស្ត្រី ដែលជាអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីសិក្សាស្វែងយល់អំពីឧបសគ្គក្នុងការបំពេញតួនាទីរបស់ពួកគាត់ ព្រមទាំងពិនិត្យមើលស្ថានភាពរបស់ស្ត្រីនៅតាមក្រសួង ស្ថាប័ន ដែលត្រូវបានតែងតាំង ថាតើស្ត្រីទាំងអស់មានការងារធ្វើពិតប្រាកដដែរឬទេ ? អ្វីខ្លះជាឧបសគ្គ ? តើមានគោលការណ៍អ្វីខ្លះក្នុងការពង្រឹងសមត្ថភាពរបស់ស្ត្រី ?

៣. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តទិតទំជួយសម្របសម្រួលក្នុងការស្វែងរកសេវាផ្លូវច្បាប់ និងសេវាផ្សេងៗទៀត សម្រាប់ផ្តល់ជូនដល់ស្ត្រីក្រីក្ររងគ្រោះដោយអំពើហិង្សា ទាំងក្នុងករណីមានបណ្តឹង ទាំងក្នុងករណីមិនមានបណ្តឹង។

៤. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តស្វែងយល់អំពីស្ថានភាពសេដ្ឋកិច្ច និងផលិតកម្មរបស់ស្ត្រីនៅជនបទក្នុងការរក្សាភាពគង់វង្សនៃសេដ្ឋកិច្ចគ្រួសារ ដូចជាការងាររបស់ស្ត្រី ដែលពុំទទួលបានប្រាក់ឈ្នួល៕

១

ដោយត្រូវយកមាត្រា១៤ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) យកមកធ្វើជាគោល ដើម្បីពិនិត្យនិងតាមដាន។

៥. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវគ្រប់គ្រងឱ្យបានហ្មត់ចត់ ចំពោះក្រុមហ៊ុនបញ្ជូនពលករ ពលការិនី ទៅធ្វើការនៅក្រៅប្រទេស ហើយសហការឱ្យបានល្អជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អ្នកតំណាងពីក្រៅប្រទេស ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្នុងការការពារសិទ្ធិនិងផលប្រយោជន៍របស់ពលករ ពលការិនី ព្រមទាំងជំរុញការអនុវត្តច្បាប់និងវិធានការនានា ក្នុងគោលដៅបង្កើនសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋ ដែលធ្វើចំណាកស្រុក ស្វែងរកការងារធ្វើនៅក្រៅប្រទេស ។

៦. ក្រសួងយុត្តិធម៌ ត្រូវបន្តបង្កើនការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ព្រមទាំងបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ស្ត្រីនិងកុមារ ដល់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ ដើម្បីធានានូវភាពយុត្តិធម៌ និងពន្លឿនការដោះស្រាយរឿងក្តីឱ្យបានឆាប់រហ័ស ជាពិសេសសំណុំរឿងក្តី ដែលពាក់ព័ន្ធនឹងស្ត្រី។

៧. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបន្តស្រង់ស្ថិតិស្តីពីជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងរៀបចំគម្រោងកម្មវិធីដើម្បីជួយអភិវឌ្ឍពួកគាត់ ព្រមទាំងបូកសរុបលទ្ធផលការងារ រៀងរាល់ឆ្នាំឆ្លើយតបទៅនឹងគោលនយោបាយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍកម្ពុជា។

៨. ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវបន្តពង្រឹងកិច្ចសហការល្អរវាងមន្ត្រីនគរបាល និងតុលាការក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅតាមសមត្ថកិច្ច និងតួនាទី ដែលបានកំណត់ក្នុងនីតិវិធីច្បាប់ជាធរមាន ដើម្បីធានាបាន ការស្វែងរកយុត្តិធម៌ជូនភាគីពាក់ព័ន្ធ ។

៩. ដើម្បីរក្សានូវវប្បធម៌ ប្រពៃណីដ៏ល្អរបស់ជាតិ ក្រសួងព័ត៌មាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបន្តត្រួតពិនិត្យតាមដានជាប្រចាំនូវរាល់ខ្លឹមសារ និងរូបភាពនៃកម្មវិធីនីមួយៗ រួមទាំងកាយវិការ ពាក្យសំដី និងសំលៀកបំពាក់ក្នុងពេលសម្តែង និងផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសតាមកញ្ចក់ទូរទស្សន៍ និងនៅលើវេទិកាផ្សេងៗទៀត។ ម្យ៉ាងទៀត ក្រសួងទាំងពីរត្រូវរៀបចំកម្មវិធីអប់រំ ពិធីករ ពិធីការិនី សិល្បករ និងសិល្បការិនី ឱ្យបានយល់ច្បាស់អំពីការស្លៀកពាក់ ដែលបង្ហាញពីវប្បធម៌ប្រពៃណីរបស់ខ្មែរទៅតាមជំនាន់នីមួយៗ។ ទន្ទឹមនឹងនេះ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងពាក់ព័ន្ធ ត្រូវពិនិត្យឱ្យបានហ្មត់ចត់លើខ្លឹមសារនិងរូបភាពនៃស្ពតទាំងឡាយ ដែលបាននិងកំពុងចាក់បញ្ចាំងតាមទូរទស្សន៍ ដោយមានវិធានការយ៉ាងម៉ឺងម៉ាត់បំផុតចំពោះស្ពតណា ដែលមានលក្ខណៈរើសអើងចំពោះស្ត្រី បន្ទាបបន្ថោកប្រពៃណី វប្បធម៌ និងតម្លៃស្ត្រីខ្មែរ។

១០. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងសាលាភូមិន្ទរដ្ឋបាល ត្រូវបង្កើនកិច្ចសហការក្នុងការបន្តអភិវឌ្ឍសមត្ថភាពដល់ស្ត្រីជាថ្នាក់ដឹកនាំថ្នាក់ក្រោមជាតិ ទាក់ទងនឹងផ្នែកមុខងារវិមជ្ឈការ ច្បាប់ បទប្បញ្ញត្តិនានា និងរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ថ្នាក់ដឹកនាំនារី ដើម្បីជួយឱ្យពួកគេអាចបំពេញតួនាទី ភារកិច្ច ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ឱ្យកាន់តែប្រសើរឡើង ព្រមទាំងរៀបចំវគ្គពិសេសសម្រាប់ស្ត្រី និងស្ត្រីវ័យក្មេង ហើយផ្ញើលទ្ធផលមកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីបូកសរុប។

១១. គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រីបន្ថែមទៀត រួមទាំងចំនួនមន្ត្រីជាស្ត្រីដែលមានសិទ្ធិសម្រេច និងត្រូវយកចិត្តទុកដាក់ក្នុងការជួយឧបត្ថម្ភគាំទ្រ ទាំងស្មារតី មធ្យោបាយ ថវិកា ព្រមទាំងផ្តល់ឱកាសឱ្យមានសំឡេងស្ត្រីចូលរួមយោបល់ក្នុងការសម្រេចតែងតាំង។ មន្ត្រីរាជការជាស្ត្រីអាចត្រូវបានតែងតាំងជំនួសមន្ត្រីទាំងឡាយ ដែលចូលនិវត្តន៍។ ដោយឡែកស្ថាប័នតុលាការ និងរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ត្រូវបន្តការលើកកំពស់បង្កើនចំនួនក្រឡាបញ្ជី មេធាវី ចៅក្រម/

និងនិស្សិតជាស្ត្រី ដើម្បីរួមចំណែកផ្តល់សេវាយុត្តិធម៌ប្រកបដោយសមធម៌ និងប្រសិទ្ធភាពចំពោះករណីអំពើហិង្សាលើស្ត្រី និងកុមារ។

១២. គ្រប់ក្រសួង ស្ថាប័នទាំងអស់ និងអាជ្ញាធរដែនដី ដោយសហការជាមួយសង្គមស៊ីវិលត្រូវយកចិត្តទុកដាក់បន្តការផ្សព្វផ្សាយ និងពង្រឹងការតាមដានការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (ស៊ី-ដ) ទៅតាមវិស័យរបស់ខ្លួន។ គ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

១៣. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តផ្តល់ថវិកាបង្កប់នៅក្នុងកញ្ចប់ថវិការបស់គ្រប់ក្រសួង ស្ថាប័ន សម្រាប់អនុវត្តការងារយេនឌ័រ ហើយនៅឆ្នាំ២០១៤ និងឆ្នាំក្រោយៗទៀត គ្រប់ក្រសួង ស្ថាប័ន ត្រូវរាយការណ៍មកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី អំពីការប្រើប្រាស់ថវិកានេះ ។

១៤. ក្រសួងអប់រំ យុវជន និងកីឡា ត្រូវពិនិត្យស្រាវជ្រាវស្ថានភាពនិស្សិតជានារី ទាំងការលំបាក និងការងាយស្រួល ទាំងក្នុងកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សា និងទាំងក្នុងគ្រឹះស្ថានរបស់រដ្ឋ និងគ្រឹះស្ថានឯកជន ព្រមទាំងធ្វើរបាយការណ៍ដោយឡែក ដើម្បីមានវិធានការដោះស្រាយ ។

១៥. ជំរុញនិងលើកកម្ពស់តួនាទីក្នុងការចូលរួម និងការទទួលបានសុវត្ថិភាពពីការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ដែលមានក្រសួងមហាផ្ទៃជាស្នូលក្នុងការដឹកនាំ និងសម្របសម្រួល។

១៦. ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង ស្ថាប័នទាំងអស់ គប្បីយកចិត្តទុកដាក់ជំរុញ និងលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាថា ស្ត្រីត្រូវទទួលបានផលប្រយោជន៍ពីការផ្តល់ សេវាសង្គម សេវាសេដ្ឋកិច្ច សេវារដ្ឋបាល និងសេវាសាធារណៈប្រកបដោយសមធម៌។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីត្រូវរៀបចំរបាយការណ៍ទូលថ្វាយ **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី អំពីលទ្ធផលនៃកិច្ចប្រជុំបូកសរុបសកម្មភាពការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ប្រចាំឆ្នាំ២០១៣ និងលើកផែនការសកម្មភាពការងារឆ្នាំ២០១៤នេះ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អសំដៅទទួលបានលទ្ធផលជាផ្លែផ្កា។

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ឆាយ ថាន់ធឿន**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការគណៈរដ្ឋាភិបាល
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់នាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

៣

# វីរនារី ស៊ន សៀវម៉ី




កីឡាការិនី **ស៊ន សៀវម៉ី** កើតនៅថ្ងៃទី១៤ កញ្ញា ឆ្នាំ១៩៩៥ ក្នុងរាជធានីភ្នំពេញ ។ ម្តាយឈ្មោះ សួន ចាន់ធី អាយុ៥៩ឆ្នាំ និងឪពុកឈ្មោះស៊ន ម៉េហ៊ាង (ស្លាប់)។ **សៀវម៉ី** ជាកូនស្រីពៅក្នុងចំណោមបងប្អូន៦នាក់(ស្រី ៣) និងបងស្រី ស៊ន ដាវីន និងបងប្រុស ស៊ន អេលីត ក៏ជាកីឡាករដ៏ល្បីឈ្មោះក្នុងពិភពកីឡាតេក្វាន់ដូផងដែរ។

**ស៊ន សៀវម៉ី** បានទទួលគ្រឿងឥស្សរិយយសជាតិថ្នាក់មហាសិរីវឌ្ឍន៍ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីកញ្ញាបានសាងស្នាដៃជូនជាតិ គឺឈ្នះមេដាយមាសពីព្រឹត្តិការណ៍កីឡាទ្វីបអាស៊ីលើកទី១៧ នៅប្រទេសកូរ៉េខាងត្បូង ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ដែលមានប្រទេសចូលរួមចំនួន ៤៥ ប្រទេស។

**ស៊ន សៀវម៉ី** ជាកីឡាការិនីតេក្វាន់ដូរបស់កម្ពុជាមួយរូប ដែលមានឆន្ទៈបញ្ចេញនូវសក្តានុពល និងទេពកោសល្យកូនខ្មែរ មានសមត្ថភាពប្រកួតប្រជែងលើឆាកអន្តរជាតិសំខាន់ៗដោយដណ្តើមបានមេដាយ ៦ គ្រឿង មានមេដាយប្រាក់ក្នុងព្រឹត្តិការណ៍កីឡាតេក្វាន់ដូកម្រិតអាស៊ាន និងមេដាយសំរិទ្ធិកម្រិតអាស៊ីអគ្នេយ៍ប្រទេសមីយ៉ាន់ម៉ា មេដាយសំរិទ្ធិក្នុងការប្រកួតជើងឯកអាស៊ីប្រទេសវៀតណាម និងមេដាយសំរិទ្ធិក្នុងពានរង្វាន់ University Games នៅប្រទេសឡាវ។ មេដាយមាស កម្រិតអាស៊ីអគ្នេយ៍ នៅប្រទេសមីយ៉ាន់ម៉ា និងឆ្នាំ២០១៤ នេះ សៀវម៉ី ទទួលបានមេដាយមាសកីឡាកម្រិតទ្វីបអាស៊ី នៅប្រទេសកូរ៉េខាងត្បូង។ ឥឡូវនេះនាងមានបំណងទៅដណ្តើមមេដាយនៅកម្រិតកីឡាខ្ពស់មួយទៀត គឺកម្រិតអូឡាំពិក។

ក្រៅពីការហ្វឹកហាត់កីឡា **សៀវម៉ី** ក៏មិនបោះបង់ចោលការសិក្សានោះដែរ នាងនិងបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច៕

***វឌ្ឍនា***

# លទ្ធផលសម្រេចបាន

## ស្ត្រីចូលរួមក្នុងវិស័យសាធារណៈ និងនយោបាយ

### .ការបោះឆ្នោតនៅថ្នាក់ជាតិ

| នីតិកាល និងឆ្នាំ | | សមាជិករដ្ឋសភា | | សមាជិកព្រឹទ្ធសភា | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១៩៩៣ | នីតិកាលទី១ | ១២០ | ៧ (៥,៨៣%) | 0 | 0 |
| ១៩៩៨ | នីតិកាលទី២ | ១២២ | ១៥ (១២,២៩%) | 0 | 0 |
| ១៩៩៩ | នីតិកាលទី១ | 0 | 0 | ៦១ | ៩(១៤,៧៥%) |
| ២០០៣ | នីតិកាលទី៣ | ១២៣ | ២៤ (១៩,៥១%) | 0 | 0 |
| ២០០៦ | នីតិកាលទី២ | 0 | 0 | ៦១ | ៩(១៤,៧៥%) |
| ២០០៨ | នីតិកាលទី៤ | ១២៣ | ២៦ (២១%) | 0 | (១៣,៥៦%) |
| ២០១៣ | នីតិកាលទី៥ | ១២៣ | ២៥ (២០,៣២%) | 0 | 0 |

## ស្ថិតិស្ត្រីជាសមាជិករាជរដ្ឋាភិបាល

| នីតិកាល និងឆ្នាំ | ឧបនាយករដ្ឋមន្ត្រី | | ទេសរដ្ឋមន្ត្រី | | រដ្ឋមន្ត្រី | | រដ្ឋលេខាធិការ | | អនុរដ្ឋលេខាធិការ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១៩៩៣ | ១ | 0(0%) | ៦ | 0 | ១៧ | 0 | ២0 | 0 | | ២ |
| ១៩៩៨ | | | | | ២៧ | ២(៧,៤%) | ៥0 | ៣(៦%) | ១២៧ | ៥(៣,៩៣%) |
| ២០០៣ | | | ១៥ | ១(៦,៦%) | ២៨ | ២(៧,១%) | ១៣៥ | ៩(៦,៦%) | ១៤៦ | ១១(៧,៥%) |
| ២០០៨ | ១0 | ១(១0%) | ១៦ | 0 | ២៦ | ២(៧,១%) | ១៩៨ | ១៦(៨%) | ២០៥ | ៣៣(១៥,១%) |
| ២០១៣ | ៩ | ១(១១.១%) | ១៥ | 0 | ២៨ | ៣(១០,៧១%) | ១៨៥ | ៣៨(២០,៥៤%) | ២៧៣ | ៤៨(១៧,៥៨%) |

## ស្ត្រីជាប់ឆ្នោតក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់

.ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ

| អាណត្តិ និងឆ្នាំ | សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ | | មេឃុំ-ចៅសង្កាត់ | | ជំទប់ទី១ | | ជំទប់ទី២ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០០២ | ១១.២១៦ | ១,០៥៦(៩,៤%) | ១៦២១ | ៤២(២,៦%) | ១៦២១ | ៧២(៤,៤%) | ១៦២១ | ៨៦(៥,៣%) |
| ២០០៧ | ១១.៣៥៣ | ១,៧១៧(១៥,១%) | ១៦២១ | ៦៧(៤,១%) | ១៦២១ | ១៥១(៩,៣%) | ១៦២១ | ១៣១(៨%) |
| ២០១២ | ១១.៤៥៩ | ២,០៣៨(១៧,៧៨%) | ១៦៣៣ | ៦៩(៤,២%) | ១៦៣៣ | ១៨៩(១១,៦%) | ១៦៣៣ | ១៥១(៩,២%) |

## ស្ថិតិស្ត្រីជាប់ឆ្នោតក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

| នីតិកាល និងឆ្នាំ | រដ្ឋលេខាធិការ | | អនុរដ្ឋលេខាធិការ | |
|---|---|---|---|---|
| | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ២០០៩ | ៣៧៤ | ៣៨(១០%) | ២.៨៦១ | ៣៦៣(១២,៦៨%) |
| ២០១៤ | ៣៩៣ | ៥២(១៣,២%) | ២.៩៣១ | ៤០៦(១៣,៨%) |

# ពិធីស្វាគមន៍ដំណើរទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូសហព័ន្ធស្ត្រី ទូទាំងប្រទេសចិន មកកាន់ព្រះរាជាណាចក្រកម្ពុជា





លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចជួបសវនាការជាមួយលោកជំទាវប្រធានគណៈប្រតិភូសហព័ន្ធស្ត្រីចិន ទូទាំងប្រទេសចិន






ដំណើរទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូសហព័ន្ធស្ត្រីទូទាំងប្រទេសចិន នៅក្រសួងកិច្ចការនារី





គណៈប្រតិភូសហព័ន្ធស្ត្រីទូទាំងប្រទេសចិន ទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីខេត្តកំពង់ឆ្នាំង




Workshop on the promotion of Access to justic for women Victims of Violence in Trafficking cases. 03-05 February 2014 Brunei.

# សកម្មភាពសំខាន់ៗរបស់ថ្នាក់ដឹកនាំក្រសួងកិច្ចការនារីឆ្នាំ២០១៤



លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារីជួបសវនាការជាមួយតំណាងស្ថានទូតស៊ុយអែតប្រចាំព្រះរាជាណាចក្រកម្ពុជា



លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារីជួបសវនាការជាមួយតំណាងស្ថានទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា

---




សិក្ខាសាលាថ្នាក់តំបន់ ដើម្បីពិភាក្សាលើការសិក្សាស្រាវជ្រាវ ដែលបានធ្វើនៅតាមប្រទេសនិមួយៗរបស់គម្រោងស្តីពី " ការតាមដាន និងជំរុញការចូលរួមរបស់ស្ត្រី ក្នុងវិស័យនយោបាយ ក្នុងតំបន់អាស៊ាន " កាលពីចុងខែមេសា ឆ្នាំ២០១៤ នៅខេត្តសៀមរាប។



លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារីថតរូបអនុស្សាវរីយ៍ជាមួយស្ត្រីថ្នាក់ដឹកនាំក្នុងតំបន់អាស៊ាន

# ការអប់រំ ដើម្បីសមភាពយេនឌ័រ





សិក្ខាសាលាពិគ្រោះយោបល់ ស្វែងយល់ស្តីពីបាតុភាពនៅក្នុងសង្គម និងផលប៉ះពាល់របស់យុវវ័យ នៅក្នុងក្រសួងកិច្ចការនារី (កុលាប១)។ សមាសភាពចូលរួមមាន ថ្នាក់ដឹកនាំក្រសួង មន្ទីរកិច្ចការនារីទូទាំងប្រទេស និងក្រសួងពាក់ព័ន្ធ សរុបចំនួន១២០ នាក់ ស្រី ៨៨នាក់។ គោលបំណងដើម្បីលើកកម្ពស់សីលធម៌សង្គម និងកាត់បន្ថយបញ្ហាខុសឆ្គងរបស់យុវវ័យ និងផ្តល់ជាអនុសាសន៍សម្រាប់អនុវត្តបន្ត។



គណៈអធិបតីក្នុងវិទ្យាល័យហ៊ុនសែនជម្ពូវ័ន



គណៈអធិបតីក្នុងសាលាជាតិកសិកម្មព្រែកលាប



គណៈអធិបតីក្នុងវិទ្យាល័យ **ហ៊ុនសែន ប៊ុនរ៉ានី** ផ្សារដើមថ្កូវ

អបអរសាទរទិវាអន្តរជាតិនារី ០៨មីនា ខួបលើកទី ១០៣ ឆ្នាំ២០១៤ ក្រោមប្រធានបទ " សមភាពនៃការអប់រំមានសារៈសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម " នៅសាលាចំនួន ៤ ៖

១. វិទ្យាល័យហ៊ុនសែនជម្ពូវ័ន

២. សាលាជាតិកសិកម្មព្រែកលាប

៣. វិទ្យាល័យ **ហ៊ុនសែន ប៊ុនរ៉ានី** ផ្សារដើមថ្កូវ

៤. វិទ្យាល័យច្បារអំពៅ

ឧបត្ថម្ភដោយៈ អង្គការ Plan អន្តរជាតិ អង្គការ Action aid, USAID, Samalimom, UNIAP និងលោកឧកញ៉ា ខូវ ផូលី។

# វេទិកា យុវជន រួមគ្នាលប់បំបាត់អំពើហិង្សាក្នុងគ្រួសារ

កាលពីពេលថ្មីៗនេះនៅខេត្តព្រះសីហនុ នាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្ត និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តបានរៀបចំវេទិកាយុវជនរួមគ្នាលប់បំបាត់អំពើហិង្សាលើស្ត្រីធ្វើឲ្យគ្រួសារមានសុភមង្គល ។ គោលបំណងនៃវេទិកានេះ គឺដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ពិសេសយុវវ័យឱ្យបានយល់ដឹងពីឫសគល់ និងផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ និងលើកទឹកចិត្តដល់យុវវ័យឱ្យចូលរួមទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងបង្កើនចំណេះដឹងដល់ពួកគេអំពីរបៀបគ្រប់គ្រងអារម្មណ៍ ដើម្បីឈានទៅរកគ្រួសារមួយមានសុភមង្គល។ វេទិកាយុវជននេះបានប្រព្រឹត្តទៅនៅវិទ្យាល័យក្រុងព្រះសីហនុ វិទ្យាល័យហ៊ុនសែនមិត្តភាព និងវិទ្យាល័យហ៊ុនសែនវាលរិញ។ អ្នកចូលរួមមាន៖ នាយក នាយករង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សរុបចំនួន ៤៥០នាក់ ក្នុងនោះស្រី ២៥០នាក់ ៕*សោភា*




លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី ជាអធិបតីក្នុងវិទ្យាល័យក្រុងព្រះសីហនុ



កញ្ញា គុណ ដាលីន សិស្សវិទ្យាល័យក្រុងព្រះសីហនុ សួរសំណួរទៅកាន់វាគ្មិន



សិស្សានុសិស្សវិទ្យាល័យហ៊ុនសែនមិត្តភាពក្នុងវេទិកា



គណៈអធិបតី ថតរូបអនុស្សាវរីយ៍ជាមួយសិស្សវិទ្យាល័យហ៊ុនសែនវាលរិញ

# ខ្លួនពិការតែចិត្តមិនពិការ



កញ្ញា ប្រាង សីហ្វ អាយុ២៧ឆ្នាំ គាត់តែងតែបង្ហាញពីភាពញញឹមរួសរាយតែនៅក្នុងក្ដីម៉ឺងម៉ាត់។ កញ្ញាជាកូនទី៤ក្នុងចំណោមបងប្អូន៥នាក់រស់នៅភូមិប៉ោយក្មៀង ឃុំព្រះនេតព្រះ ស្រុកព្រះនេតព្រះ ខេត្តបន្ទាយមានជ័យ។ កញ្ញាជានារីម្នាក់ពិការតាំងពីកំណើត (គមខ្នង) ដែលមានប្រវត្តិជូរចត់មួយរូបក្នុងចំណោមជនពិការជាច្រើននៅទូទាំងខេត្ត រស់នៅលំបាកតោកយ៉ាកក្រីក្រជាមួយម្ដាយដែលជាស្ត្រីមេមាយ ដែលឪពុកស្លាប់ចោលតាំងពីអាយុ៨ឆ្នាំ។

ជាការពិតណាស់ដោយការខិតខំប្រឹងប្រែង នឹងមានការលើកទឹកចិត្តពីក្រុមគ្រួសារញាតិមិត្តជិតខាង ជាពិសេស កញ្ញាចូលបំរើការងារក្រុបខណ្ឌមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ បានជាប់ជាមន្ត្រីឆ្នាំ២០១៣។ ពេលនោះខ្ញុំមានអារម្មណ៍សប្បាយចិត្តមានការងារច្បាស់លាស់មិនតែលតោលដូចមុន។ កញ្ញាបានរៀបរាប់ទាំងទឹកភ្នែកតិចៗថា ទោះបីខ្ញុំជួបការលំបាកយ៉ាងណាក៏ដោយខ្ញុំមិនតូចចិត្តនឹងខ្លួនឯងនោះទេ ត្បិតធម្មជាតិកំណត់ឱ្យរូបពិការភាព ហើយក៏មានការរើសអើងខ្លះពីអ្នកដទៃយ៉ាងណាក៏មែនពិត ប៉ុន្តែចិត្តមិនពិការនោះទេ។ កញ្ញាបានខិតខំតស៊ូជំនះគ្រប់ការលំបាកព្យាយាមក្នុងការសិក្សា តាំងពីបឋមសិក្សារហូតបញ្ចប់ថ្នាក់ឧត្ដមសិក្សានៅត្រឹមសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) ចុងឆ្នាំ២០០៩។ បន្ទាប់ពីការសិក្សា កញ្ញាបានចូលបំរើការងារតាមសហាគមន៍ និងនៅមជ្ឈមណ្ឌលអង្គការ(PDP) ក្នុងការរួមចំណែកជួយដល់សង្គម។

កញ្ញាក៏បានផ្ដាំផ្ញើដល់ជនពិការទាំងអស់ថា មិនត្រូវអស់សង្ឃឹមក្នុងជីវិតនោះទេ គឺត្រូវតែក្រោកឈរឡើងខិតខំកសាង ពង្រឹងសមត្ថភាពដោយខ្លួនឯង ជំនះរាល់ឧបសគ្គចំពោះមុខ នឹងសំណូមពរដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានកុំវាយតម្លៃ ឬរើសអើងជនពិការ ផ្ទុយទៅវិញជួយជំរុញ និងលើកទឹកចិត្តតាមរយៈផ្ដល់ឱកាសចូលរួមគ្រប់ការងារនៅក្នុងសង្គម ព្រោះជនពិការក៏មានសិទ្ធិដូចមនុស្សទូទៅដែរ៕ *ធីណា*

**គួរយល់ដឹង**

# គួរជៀសវាងការពន្លូតកូន បើមិនមានការចាំបាច់

យុគសម័យថ្មីយើងនេះ បញ្ហាពន្លូតកូនដោយការលួចលាក់ ឬដោយចំហរក្តី នឹងកំពុងកើតមានដោយចំណែកណាមួយក្នុងស្រទាប់យុវវ័យ ពិសេសយុវវ័យដែលផុងខ្លួនក្នុងចំណងស្នេហាក្រៅអាពាហ៍ពិពាហ៍ ក្នុងនោះដែលគូភាគីទាំងពីរកំពុងស្ថិតក្នុងការសិក្សា។

ជាទូទៅការមានគភ៌ គឺជារឿងដែលក្រុមគ្រួសារបានទទួលភាពសប្បាយរីករាយបំផុត ព្រោះគេគិតថា នេះជាចំណងដៃដ៏សុភមង្គលនៃគូស្វាមីភរិយា ដែលត្រូវបានរៀបចំឡើងតាមគន្លងប្រពៃណី និងច្បាប់របស់ប្រទេសជាតិខ្លួន ប៉ុន្តែផ្ទុយទៅវិញការមានគភ៌ដោយលួចលាក់ ឬក្រៅចំណងអាពាហ៍ពិពាហ៍ គឺត្រូវបានសង្គមចាត់ទុកជារឿងអាម៉ាស់បំផុត។ដោយឡែកសម្រាប់គ្រួសារដែលមានការរៀបចំផ្សំផ្គុំតាមលក្ខណៈច្បាប់ និងប្រពៃណីទំនៀមទម្លាប់ខ្មែរ ហើយប្រសិនបើយល់ថាកាលៈទេសៈណាមួយខ្លួនពុំទាន់ចង់បានបុត្រទេ គួរប្រើវិធីការពារឱ្យបានជាមុនប្រសើរជាងរឿងរ៉ាវដែលកើតមានរួចហើយបែរជារកវិធីផ្សេងៗដើម្បីយកកូននោះចេញ ពិសេសការពន្លូតកូននេះឯង ដែលករណីបែបនេះនឹងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពផ្ទាល់ខ្លួន ពិសេសប៉ះពាល់ដល់សីលធម៌សង្គម ទំនៀមទម្លាប់ក្នុងជំនឿព្រះពុទ្ធសាសនាយ៉ាងខ្លាំង។ ដើម្បីការពារកុំឱ្យឈានដល់ដំណាក់កាលពន្លូតកូននេះ ក្រុមគ្រួសារ ពិសេសដៃគូយុវវ័យ គួរសិក្សាជ្រើសរើសវិធានការការពារដោយកុំឱ្យការប្រព្រឹត្តផ្លូវភេទរបស់លោកអ្នកជួបប្រទះនូវការមានផ្ទៃពោះដែលខ្លួនមិនទាន់ចង់បាន គួរជ្រើសរើសយកការប្រើប្រាស់ស្រោមអនាម័យ ឬក៏ប្រើឱសថការពារឱ្យបានត្រឹមត្រូវ។

ពាក់ព័ន្ធទៅនឹងការមានផ្ទៃពោះដោយចៃដន្យ ហើយមិនចង់បាននោះ ភាគច្រើននៃស្ត្រី ឬក្រុមគ្រួសារចូលចិត្តជ្រើសរើសយកវិធីពន្លូតកូនដោយពុំបានគិតគូរអំពីគ្រោះថ្នាក់ជាយថាហេតុជាមួយអ្នកគ្មានជំនាញវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រ។ ប្រការនេះសម្រាប់ជាដំបូន្មានដល់ក្រុមគ្រួសារ ឬស្ត្រីផ្ទាល់ គួរតែស្វែងរកវិធីដោះស្រាយនូវសុខភាពល្អបរិបូរណ៍ទាំងមាតានិងទារក។

ការកាត់បន្ថយមួយបែបទៀត គឺផ្តល់សិទ្ធិឱ្យយុវវ័យបានយល់ដឹងស៊ីជម្រៅរាល់ព័ត៌មានមួយចំនួន ដែលទាក់ទងទៅនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ដោយផ្តល់ឱកាសឱ្យយុវវ័យបានចូលរួមពិភាក្សាអំពីមធ្យោបាយពន្យារកំណើតជាមួយដៃគូរបស់គេ។ សំខាន់ត្រូវឱ្យគេចេះការពារកុំឱ្យមានគភ៌ ដើម្បីកុំឱ្យគេឈានទៅការសម្រេចចិត្តពន្លូតកូន ដែលជារឿងគ្រោះថ្នាក់បំផុតនោះ។ មាត្រាទី៨ នៃច្បាប់ពន្លូតកូននោះចែងច្បាស់ថា ការរំលូតកូនអាចធ្វើទៅបានចំពោះតែគភ៌ណាដែលមានអាយុតិចជាង ១២ សប្តាហ៍។ លើសពី ១២ សប្តាហ៍នៃអាយុគភ៌ ការរំលូតកូនអាចទទួលការអនុញ្ញាតបាន លុះត្រាតែក្នុងពេលធ្វើរោគវិនិច្ឆ័យឃើញថា គភ៌មានភាវនីយភាពលូតលាស់មិនដូចប្រក្រតី ឬ បង្កគ្រោះថ្នាក់ដល់ជីវិតម្តាយ។ កូនដែលនឹងកើតអាចមានជម្ងឺធ្ងន់ធ្ងរព្យាបាលមិនជា។ ក្នុងករណីដែលគេរំលោភបណ្តាលឱ្យមានគភ៌ ការរំលូតកូនអាចប្រព្រឹត្តទៅបានដោយមិនគិតពីល័ក្ខខ័ណ្ឌដូចមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមានអាយុ១៨ឆ្នាំឡើងទៅ ឬការស្នើសុំដោយទទួលពីអាណាព្យាបាល និងសាមីខ្លួន បើស្ត្រីមានគភ៌អាយុតិចជាង ១៨ ឆ្នាំ។ ការសម្រេចបញ្ហានេះត្រូវមានការឯកភាពពីក្រុមគ្រូពេទ្យពីរ ឬបីនាក់រួមទាំងសាមីខ្លួន ល័ក្ខខ័ណ្ឌបច្ចេកទេសសម្រាប់ការអនុវត្តន៍នៃមាត្រានេះ។

មាត្រាទី១៤ ចែងថា ជនទាំងឡាយណាដែលបង្ខិតបង្ខំឱ្យស្ត្រីមានគភ៌ ឬធ្វើឱ្យរំលូតកូនដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ ឆ្នាំ។ បើមានការបង្ខិតបង្ខំឱ្យស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើឱ្យរំលូតកូនដោយចេតនានោះ បណ្តាលឱ្យស្ត្រីដែលមានគភ៌មានជម្ងឺរ៉ាំរ៉ៃ ឬពិការ ឬបណ្តាលឱ្យស្លាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ទៅ ១០ ឆ្នាំ៕

*ស្រាវជ្រាវដោយសោភា*




ថ្ងៃជោគជ័យរបស់ កញ្ញា សិន សៀវមុី នៅ

Inchoen ប្រទេសកូរ៉េខាងត្បូង